ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខៈ ០១ សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០៣

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានកិត្តិយសជូនដំណឹងដល់គ្រប់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ថា យោងតាមសំណូមពររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមលិខិតលេខ ១២.០៨៨/០២ គ.ជ.ប ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០២ លោកនាយក ឬម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវបង្កលក្ខណៈ និងអនុញ្ញាតអោយកម្មករនិយោជិតទៅពិនិត្យផ្ទៀងឈ្មោះរបស់ខ្លួនជាមួយបញ្ជីបោះឆ្នោត ឆ្នាំ ២០០២ ទៅចុះឈ្មោះបោះឆ្នោត ព្រមទាំងទៅចូលរួមការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទដូចខាងក្រោម :

- នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣ គ.ជ.ប នឹងធ្វើការបិទផ្សាយបញ្ជីបោះឆ្នោតឆ្នាំ ២០០២ នៅតាមសាលា ឃុំ-សង្កាត់ និងនៅតាមការិយាល័យបោះឆ្នោតឆ្នាំ ២០០២ ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋមកពិនិត្យឈ្មោះរបស់ខ្លួន ។

- ការចុះឈ្មោះបោះឆ្នោតមានរយៈពេល ៣០ ថ្ងៃ គឺចាប់តាំងពីថ្ងៃទី ១៧ ខែមករា ដល់ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៣ នឹងត្រូវធ្វើនៅសាលាឃុំ-សង្កាត់ ឬនៅតាមការិយាល័យចុះឈ្មោះណាមួយក្នុងឃុំ-សង្កាត់ ។

-ការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ។ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យណា ត្រូវទៅបោះឆ្នោតនៅការិយាល័យនោះ ។

ក្នុងគោលបំណងបង្កលក្ខណៈឱ្យនិយោជិត កម្មករ កម្មការិនីបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមបោះឆ្នោតប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងប្រជាធិបតេយ្យ ចំនួនថ្ងៃដែលត្រូវអនុញ្ញាតជូនកម្មករ និយោជិត សំរាប់សកម្មភាពខាងលើនេះ ត្រូវប្រព្រឹត្តតាមការកំណត់ដូចខាងក្រោមនេះ :

74

-ចំពោះនិយោជិត កម្មករ កម្មការិនី ដែលអនុវត្តបានហួសពីច្បាប់អនុញ្ញាតដូចមានចែងខាងលើ ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន។

-និយោជកត្រូវខិតខំបើកប្រាក់ឈ្នួលឱ្យនិយោជិត កម្មករ កម្មការិនី អោយបានមុនថ្ងៃពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ព្រមទាំងថ្ងៃទៅបោះឆ្នោត។ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ទេ សូមអនុញ្ញាតឱ្យនិយោជិត កម្មករ កម្មការិនី ខ្ចីប្រាក់ឈ្នួលបួយភាគ (បុរេប្រទាន) ជាមុនសិន។

ក្រសួងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោកជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ និយោជិត កម្មករ កម្មការិនីនឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាព។

រដ្ឋមន្ត្រី

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ